

ធនាគារ ប្រៃសណីយ៍កម្ពុជា
東埔寨郵政銀行 CAMBODIA POST BANK

# ព្រឹត្តិបត្រព័ត៌មាន

ខែមករា ឆ្នាំ២០២៦ | លេខ១០



## សេដ្ឋកិច្ច និងវិស័យធនាគារនៅក្នុងប្រទេសកម្ពុជា

សេដ្ឋកិច្ចកម្ពុជាកំពុងប្រឈមមុខនឹងអស្ថិរភាព ដែលភាគច្រើនបណ្តាលមកពីសម្ពាធក្រៅស្រុក និងបញ្ហាវិស័យហិរញ្ញវត្ថុក្នុងស្រុក។ ការព្រួយបារម្ភខ្លាំងជាងគេ គឺភាពមិនប្រាកដប្រជា អំពីរយៈពេល និងទំហំនៃការយកពន្ធខ្ពស់របស់សហរដ្ឋអាមេរិកមកលើកម្ពុជា និងជម្លោះព្រំដែនជាមួយប្រទេសថៃ។

- ការព្យាករណ៍កំណើនសេដ្ឋកិច្ចរបស់កម្ពុជា ត្រូវបានកែសម្រួលចុះមកត្រឹម ៤,៩% សម្រាប់ឆ្នាំ២០២៥ និង ៥.0% សម្រាប់ឆ្នាំ២០២៦។ សេដ្ឋកិច្ចកម្ពុជា មានកំណើនល្អនៅឆមាសទីមួយ នៃឆ្នាំ២០២៥ ប៉ុន្តែឆមាសទី២ ត្រូវបានគេរំពឹងថានឹងថយចុះ ដោយសារតែភាពតានតឹងនៅតាមព្រំដែនជាមួយប្រទេសថៃ និងផលប៉ះពាល់នៃភាពមិនប្រាកដប្រជានៃគោលនយោបាយពាណិជ្ជកម្មរបស់សហរដ្ឋអាមេរិក។
- អតិផរណាត្រូវបានគេព្យាករថា នឹងថយចុះ ដោយសារតែការកើនឡើងយឺតនៃតម្លៃម្ហូបអាហារ និងការធ្លាក់ចុះនៃតម្លៃប្រេងឥន្ធនៈ។ អតិផរណាបានធ្លាក់ចុះពី ៦,0% ក្នុងខែមករា មកត្រឹម ១,៦% ក្នុងខែមិថុនា ដែលភាគច្រើនមកពីការកើនឡើងតិចតួចនៃតម្លៃម្ហូបអាហារ។ ការធ្លាក់ចុះនៃតម្លៃប្រេងឥន្ធនៈក៏បានជួយកាត់បន្ថយការកើនឡើងនៃតម្លៃទំនិញផ្សេងៗផងដែរ។ ក្នុងរយៈពេល ១២ខែ ជាមធ្យម អត្រាអតិផរណាកើនឡើង ២,៤% ក្នុងខែមិថុនា និងអាចមានស្ថិរភាពក្នុងកម្រិត ២,0% នៅក្នុងឆ្នាំ ២០២៥ និងឆ្នាំ ២០២៦។
- វិស័យឧស្សាហកម្មនៅតែជាកត្តាចម្បងក្នុងការជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ដោយត្រូវបានគេព្យាករថា ជាមធ្យមនឹងកើនឡើង ដល់ ៧,៩% ក្នុងឆ្នាំ ២០២៥ និង ៨,៣% ក្នុងឆ្នាំ ២០២៦។
- ការនាំចេញសម្លៀកបំពាក់បានកើនឡើង ២២,២% ក្នុងឆមាសទី១ ឆ្នាំ២០២៥ ដែលជំរុញមួយផ្នែកដោយសារ អ្នកទិញនៅសហរដ្ឋអាមេរិកបានទិញទំនិញដើម្បីស្តុកទុក មុនពេលការដំឡើងពន្ធលើទំនិញនាំចូលពីកម្ពុជា។ ទោះជាយ៉ាងណាក៏ដោយ វិស័យកាត់ដេរសម្លៀកបំពាក់ទំនងជានៅតែរឹងមាំ ដោយសារការបន្ទាបពន្ធនាំចូលរបស់សហរដ្ឋអាមេរិក មកត្រឹម ១៩% ដែលមានប្រសិទ្ធភាពចាប់ពីថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៥ ទោះបីជាអ្នកទិញមួយចំនួននៅតែមានការប្រុងប្រយ័ត្នក្នុងបញ្ជាទិញដោយសារតែភាពមិនប្រាកដប្រជានៃគោលនយោបាយពាណិជ្ជកម្មក៏ដោយ។ ក្រៅពីសម្លៀកបំពាក់ ការនាំចេញទំនិញផ្សេងៗក៏បានកើនឡើង ៨,៨% ដែលភាគច្រើនជា ខ្សែភ្លើង ខ្សែកាបអុបទិក សម្ភារៈធ្វើពីឈើ និងកង់។

- កំណើនក្នុងវិស័យសេវាកម្មត្រូវបានគេរំពឹងថានឹងថយចុះមកត្រឹម ២,៨% ក្នុងឆ្នាំ ២០២៥ និង ២,៦% ក្នុងឆ្នាំ ២០២៦។ វិស័យទេសចរណ៍បានបន្តងើបឡើងវិញនៅក្នុងឆ្នាំ ២០២៥ ជាមួយនឹងការកើនឡើងនៃភ្ញៀវទេសចរណ៍មកពីសាធារណៈរដ្ឋប្រជាមានិតចិន។ ប៉ុន្តែភាពតានតឹងនៅតាមព្រំដែនជាមួយប្រទេសថៃ នឹងកាត់បន្ថយភ្ញៀវទេសចរណ៍ចេញពីប្រទេសថៃ ហើយអាចប៉ះពាល់ដល់អាជីវកម្ម និងសេវាកម្មនានានៅតាមព្រំដែន ក្នុងឆមាសទី២ ឆ្នាំ២០២៥ និងឆ្នាំបន្ទាប់ផងដែរ។

- វិស័យកសិកម្មបន្តរីកចម្រើនជាលំដាប់។ វិស័យនេះត្រូវបានព្យាករថានឹងមានកំណើន១,១% ក្នុងឆ្នាំ២០២៥ និង២០២៦ ដោយសារមានតម្រូវការនាំចេញ។ ការនាំចេញកសិផលបានកើនឡើង ១៤,១% ក្នុងឆមាសទី១ ឆ្នាំ២០២៥ ស្មើនឹង ១,៩ ពាន់លានដុល្លារ។ កំណើននេះបានដោយសារការកើនឡើងនៃការនាំចេញគ្រាប់ស្វាយចន្ទី និងអង្ករ ខណៈការនាំចេញដំឡូងមី និងកៅស៊ូមានការថយចុះ។

- ការវិនិយោគពីបរទេសនៅតែមានការកើនឡើង។ លំហូរវិនិយោគផ្ទាល់ពីបរទេសបានកើនឡើង ៦,១%ក្នុងត្រីមាសទីមួយនៃឆ្នាំ ២០២៥ ស្មើនឹង ១ពាន់លានដុល្លារ។

- ទុនបម្រុងអន្តរជាតិសរុបបានកើនឡើងដល់ ២៤,៨ពាន់លានដុល្លារនៅពាក់កណ្តាលឆ្នាំ ២០២៥ កើនឡើងពី ២២,៥ ពាន់លានដុល្លារនៅចុងឆ្នាំ ២០២៤ ដែលគ្រប់គ្រាន់សម្រាប់ចំណាយលើការនាំចូលរយៈពេល ៧,៨ ខែ។

- កំណើនសេដ្ឋកិច្ច អាចប្រឈមនឹងហានិភ័យអវិជ្ជមាន ដែលរួមមានកំណើនយឺតនៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿន ភាពតានតឹងនៅតាមបន្ទាត់ព្រំដែនជាមួយប្រទេសថៃ ភាពមិនប្រាកដប្រជានៃគោលនយោបាយពាណិជ្ជកម្មសកល និងបំណុលឯកជនដ៏ច្រើនលើសលុប។







ដើម្បីឱ្យការអភិវឌ្ឍន៍សេដ្ឋកិច្ច និងភាពធន់របស់កម្ពុជាមាននិរន្តរភាព កម្ពុជាទាមទារឱ្យមានការពន្លឿនកំណែទម្រង់រចនាសម្ព័ន្ធ ដែលនឹងពង្រឹងសមត្ថភាពផលិត និងការធ្វើពិពិធកម្មវិស័យនានាដែលអាចជួយជំរុញកំណើនសេដ្ឋកិច្ច។ នៅចុងឆ្នាំ២០២៩ កម្ពុជាអាចនឹងលុបឈ្មោះចេញពីក្រុមប្រទេសដែលមានការអភិវឌ្ឍតិចតួច ដែលនេះនឹងនាំមកនូវការប្រកួតប្រជែងថ្មីៗ និងការបង្កើនផលិតភាពរបស់កម្ពុជា។ គម្រោងអាទិភាពរួមមាន ការលើកកម្ពស់បរិយាកាសធុរកិច្ច ដោយពង្រឹងអភិបាលកិច្ច និងកិច្ចខិតខំប្រឹងប្រែងប្រឆាំងអំពើពុករលួយ ការកែលម្អនីតិរដ្ឋ សិទ្ធិអចលនទ្រព្យ ការទទួលបានព័ត៌មាន ការពង្រឹងសំណាញ់សុវត្ថិភាពសង្គម និងការវិនិយោគលើធនធានមនុស្ស ដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស និងត្រៀមខ្លួនផ្លាស់ប្តូរឆ្ពោះទៅកាន់ឧស្សាហកម្មដែលផ្តល់តម្លៃបន្ថែមខ្ពស់។

រដ្ឋាភិបាលកម្ពុជាបានដំឡើងថវិកាសម្រាប់ឆ្នាំ២០២៦ ដល់ ១០ពាន់លានដុល្លារ កើនឡើង៧,៨%ធៀបនឹងការចំណាយក្នុងឆ្នាំ២០២៥។ ការដំឡើងថវិកានេះ គឺដើម្បីលើកកម្ពស់ភាពធន់របស់កម្ពុជា តាមរយៈការពង្រឹងផលិតភាពសេដ្ឋកិច្ច ការប្រកួតប្រជែង ការការពារសង្គម ការអភិវឌ្ឍន៍ធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធ ការការពារជាតិ កំណែទម្រង់អភិបាលកិច្ច និងការកសាងនីតិរដ្ឋ។

ការបង្កើនកញ្ចប់ថវិការបស់កម្ពុជាសម្រាប់ឆ្នាំ២០២៦ និងគម្រោងដែលអនុញ្ញាតឱ្យភ្ញៀវទេសចរណ៍ចិនមកកម្សាន្តនៅប្រទេសកម្ពុជាដោយមិនចាំបាច់មានទិដ្ឋាការ ដែលនឹងត្រូវអនុវត្តចាប់ពីថ្ងៃទី១៥ ខែមិថុនា ដល់ថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២៦ អាចនឹងផ្តល់អត្ថប្រយោជន៍ជាច្រើនដល់កម្ពុជា។ ប្រសិនបើគម្រោងសាកល្បងនេះទទួលបានជោគជ័យក្នុងការធ្វើឱ្យវិស័យទេសចរណ៍ និងសេវាកម្មពាក់ព័ន្ធនានាងើបឡើងវិញ គម្រោងនេះនឹងជួយកម្ពុជា ទប់ទល់នឹងសម្ពាធពីខាងក្រៅ ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា និងរក្សាអត្រាមានការងារធ្វើរបស់ប្រជាជនកម្ពុជាផងដែរ។

*Source: Asian Development Outlook Sep.2025 by ADB & AMRO Annual Consultation Report Cambodia – 2025 dated Aug 2025, IMF Report released on Sep 2025, China Daily dated 6th Dec 2025.*

# ធនាគារ ប្រៃសណីយ៍កម្ពុជា ចូលរួមនាំយកអំណោយ និងថវិកា ជូនរដ្ឋបាលខេត្តព្រះវិហារ និងឧត្តរមានជ័យ



គណៈគ្រប់គ្រង ធនាគារ ប្រៃសណីយ៍កម្ពុជា បានចូលរួមឧបត្ថម្ភ និងរួមដំណើរជាមួយ សមាគមធនាគារនៅកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា ដោយបាននាំយកជំនួយសប្បុរសធម៌ និងថវិកា២៤០ លានរៀល ជូនដល់រដ្ឋបាលខេត្តព្រះវិហារ និងរដ្ឋបាលខេត្តឧត្តរមានជ័យ នៅថ្ងៃទី១១ និង១២ ខែតុលា ឆ្នាំ២០២៥ ដើម្បីចាត់ចែង និងផ្តល់ជូនបងប្អូនប្រជាពលរដ្ឋដែលបានជម្លៀសទៅកាន់ទីតាំងសុវត្ថិភាព និងវីរកងទ័ព ដែលឈរជើងតាមខ្សែបន្ទាត់ព្រំដែនក្នុង ភូមិសាស្ត្រខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ។ ជំនួយសប្បុរសធម៌រួមមាន គ្រឿងឧបភោគបរិភោគ ទឹកបរិសុទ្ធ ៤០០កេស មី ៤០០កេស ត្រីខ ៤០០យួរ ទឹកត្រី ៤០០ដប ទឹកស៊ីអ៊ីវ ៤០០យួរ និងសម្ភារៈប្រើប្រាស់ចាំបាច់មួយចំនួនដូចជា សារ៉ុង ៤០០ ក្រម៉ា ៤០០ សាប៊ូ ៤០០ប្រអប់ និងអង្រឹង ៥៨០ ។












# គណៈគ្រប់គ្រងធនាគារ ប្រៃសណីយ៍កម្ពុជា ចូលរួមអបអរពិធីសម្ពោធអាកាសយានដ្ឋានអន្តរជាតិតេជោ







ថ្នាក់ដឹកនាំធនាគារ ប្រៃសណីយ៍កម្ពុជា បានចូលរួម អបអរសាទរ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអាកាសយានដ្ឋានអន្តរជាតិតេជោ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជានៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៥។

**"អាកាសយានដ្ឋានអន្តរជាតិតេជោ"** ដែលជាស្នាដៃដ៏ធំ ជាមោទនភាពថ្មីមួយរបស់កម្ពុជា និងជាច្រកទ្វារថ្មីរបស់កម្ពុជាឆ្ពោះទៅកាន់ពិភពលោក។

ធនាគារ ប្រៃសណីយ៍កម្ពុជា មានមោទភាពដែលបានក្លាយជាផ្នែកមួយនៃដំណើរប្រវត្តិសាស្រ្តនេះដោយធនាគារបានផ្តល់សេវាកម្ម ATM និងរៀបចំក្រុមការងារដើម្បីត្រៀមបើកគណនី និងដាក់ឱ្យដំណើរការ CPBank Mobile Banking ជូនអ្នកដំណើរ និងភ្ញៀវទេសចរ នៅស្ថានីយអ្នកដំណើរមកដល់ផងដែរ។



# ធនាគារ ប្រៃសណីយ៍កម្ពុជា បានរៀបចំកម្មវិធី «បរិច្ចាគផ្តល់ឈាម»




នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៥ ធនាគារ ប្រៃសណីយ៍កម្ពុជា បានរៀបចំកម្មវិធីបរិច្ចាគឈាមដោយស្ម័គ្រចិត្ត នៅមជ្ឈមណ្ឌលជាតិផ្តល់ឈាម ដើម្បីរួមចំណែកក្នុងការជួយសង្គ្រោះជីវិតអ្នកជំងឺ ដែលកំពុងត្រូវការឈាម។

កម្មវិធីបរិច្ចាគឈាមដោយស្ម័គ្រចិត្តនេះ ត្រូវបានរៀបចំឡើង នៅ៤ទីតាំងផ្សេងគ្នាក្នុងពេលតែមួយ គឺនៅមជ្ឈមណ្ឌលជាតិផ្តល់ឈាមនៅរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តបាត់ដំបង និងខេត្តកំពង់ចាម ដោយមានការចូលរួមពីគណៈគ្រប់គ្រង បុគ្គលិកមកពីស្នាក់ការកណ្តាល និង៣៣សាខា នៅរាជធានីភ្នំពេញ ខេត្ត និងស្រុក របស់ធនាគារ ប្រៃសណីយ៍កម្ពុជា និងគណៈគ្រប់គ្រង និងបុគ្គលិកហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី ផងដែរ។











# ធនាគារ ប្រៃសណីយ៍កម្ពុជា ឧបត្ថម្ភ កម្មវិធី “ទិវាសន្សំអាស៊ាន”




ធនាគារ ប្រៃសណីយ៍កម្ពុជា ឧបត្ថម្ភ កម្មវិធី **“ទិវាសន្សំអាស៊ាន”** រៀបចំឡើងដោយ ធនាគារជាតិនៃកម្ពុជា នៅខេត្តកំពត ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៥ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃការសន្សំប្រាក់។

កម្មវិធីនេះត្រូវបានប្រារព្ធឡើងក្រោមប្រធានបទ **“សន្សំប្រាក់ដោយភាពវៃឆ្លាត សន្សំប្រាក់ដោយក្តីស្រឡាញ់”** ដែលជាការអំពាវនាវដល់សាធារណជនគ្រប់រូបឱ្យមានទម្លាប់សន្សំប្រាក់ដោយមានការគិតគូរ និងសម្រាប់អនាគតដ៏ល្អប្រសើររបស់ខ្លួន និងក្រុមគ្រួសារ។











# សេចក្ដីជូនដំណឹងស្ដីពី ការផ្លាស់ប្ដូរទីតាំង និងឈ្មោះសាខា របស់ធនាគារ ប្រៃសណីយ៍កម្ពុជា







គណៈគ្រប់គ្រង ធនាគារ ប្រៃសណីយ៍កម្ពុជា មានកិត្តិយសសូមជម្រាបជូន ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី ជាអតិថិជន និងសាធារណជនទាំងអស់មេត្តាជ្រាបថា៖

ដើម្បីផ្ដល់ភាពងាយស្រួល និងប្រសិទ្ធភាពខ្ពស់ក្នុងការផ្ដល់សេវាកម្មជូនអតិថិជន ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ **«សាខាសុវណ្ណា»** នឹងត្រូវប្ដូរឈ្មោះ និងផ្លាស់ប្ដូរទៅកាន់ទីតាំងថ្មី ដោយកំណត់ឈ្មោះជាផ្លូវការថា៖

- **សាខាក្រុមហ៊ុនក្នុងស្រុក ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ (ខណ្ឌបឹងកេងកង - សង្កាត់ទួលស្វាយព្រៃទី១)**
- **អាសយដ្ឋានថ្មី៖ ផ្ទះលេខ១៩៩ មហាវិថីម៉ៅសេទុង ភូមិ៦ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។**

អាស្រ័យហេតុនេះ សូមអតិថិជន និងសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។ យើងខ្ញុំរីករាយស្វាគមន៍យ៉ាងកក់ក្ដៅក្នុងការផ្ដល់សេវាកម្មហិរញ្ញវត្ថុដ៏សម្បូរបែបជូនលោកអ្នកនៅទីតាំងថ្មីនេះ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រ និងការជឿទុកចិត្តរបស់លោកអ្នកមកលើ ធនាគារ ប្រៃសណីយ៍កម្ពុជា កន្លងមក។










# ធនាគារ ប្រៃសណីយ៍កម្ពុជា និងហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី រៀបចំការប្រកួតបាល់ទាត់មិត្តភាព ដើម្បីរឹតចំណងសាមគ្គីភាព

នៅល្ងាចថ្ងៃពុធ ទី០៣ ខែធ្នូ ឆ្នាំ២០២៥ ធនាគារ ប្រៃសណីយ៍កម្ពុជា និងហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បានសហការគ្នារៀបចំព្រឹត្តិការណ៍ប្រកួតបាល់ទាត់មិត្តភាពដ៏សប្បាយរីករាយមួយ ដែលបានប្រព្រឹត្តទៅនៅទីលានបាល់ទាត់ T-Soccer ។

ការប្រកួតនេះមិនត្រឹមតែជាការលេងកីឡាដើម្បីសុខភាពប៉ុណ្ណោះទេ ប៉ុន្តែត្រូវបានបង្កើតឡើងក្នុងគោលបំណងយ៉ាងសំខាន់ ដើម្បីពង្រឹងចំណងមិត្តភាព សាមគ្គីភាព និងបង្កើនទំនាក់ទំនងកិច្ចសហប្រតិបត្តិការល្អ រវាងថ្នាក់ដឹកនាំ និងបុគ្គលិកនៃស្ថាប័នហិរញ្ញវត្ថុទាំងពីរ។ បរិយាកាសនៃការប្រកួតពោរពេញទៅដោយស្នាមញញឹម ភាពស្និទ្ធស្នាល និងស្មារតីកីឡា ដែលឆ្លុះបញ្ចាំងពីភាពជាដៃគូដ៏រឹងមាំក្នុងគ្រួសារតែមួយនៃវិស័យហិរញ្ញវត្ថុ។

ព្រឹត្តិការណ៍នេះក៏ជាផ្នែកមួយនៃការលើកកម្ពស់សុខុមាលភាពបុគ្គលិក និងការកសាងក្រុមការងារ (Team Building) តាមរយៈវិស័យកីឡាផងដែរ។










# ធនាគារ ប្រៃសណីយ៍កម្ពុជា បង្ហាញវត្តមាន និងផលិតផលហិរញ្ញវត្ថុឌីជីថល ក្នុង «វេទិការដ្ឋាភិបាលឌីជីថល ឆ្នាំ២០២៥»




រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០២៥ – ធនាគារ ប្រៃសណីយ៍កម្ពុជា មានកិត្តិយស និងសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបានចូលរួមជាផ្នែកមួយនៃ **«វេទិការដ្ឋាភិបាលឌីជីថល ឆ្នាំ២០២៥» (Digital Government Forum 2025)** ដែលប្រារព្ធឡើងក្រោមប្រធានបទដ៏មានសារៈសំខាន់គឺ «ពន្លឿនអនាគតឌីជីថល៖ អភិបាលកិច្ច ភាពរីកចម្រើន និងភាពជាដៃគូសកល»។











# គណៈគ្រប់គ្រង និងបុគ្គលិក ធនាគារ ប្រៃសណីយ៍កម្ពុជា ចូលរួមបរិច្ចាគឈាមដោយស្ម័គ្រចិត្ត ដើម្បីគាំទ្រវីរកងទ័ពជួរមុខ





រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២៥ – តបតាមការអំពាវនាវដ៏ខ្ពង់ខ្ពស់របស់ លោកជំទាវទី១ និងក្រោមស្មារតី **«ខ្មែរតែមួយ»** នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២៥ គណៈគ្រប់គ្រង និងបុគ្គលិករបស់ធនាគារ ប្រៃសណីយ៍កម្ពុជា បានចូលរួមក្នុងពិធីបរិច្ចាគឈាមដោយស្ម័គ្រចិត្ត ដែលបានប្រារព្ធធ្វើឡើងនៅ សាកលវិទ្យាល័យការពារជាតិ។

សកម្មភាពមនុស្សធម៌នេះធ្វើឡើងក្នុងគោលបំណងបង្ហាញនូវសាមគ្គីភាព និងការគាំទ្រយ៉ាងពេញទំហឹងពីសំណាក់វិស័យឯកជន និងប្រជាពលរដ្ឋ ដើម្បីជាកម្លាំងចិត្តជូនដល់វីរកងទ័ពជួរមុខដែលកំពុងបំពេញបេសកកម្មការពារជាតិមាតុភូមិ។ ការចូលរួមបរិច្ចាគឈាមនាពេលនេះ មិនត្រឹមតែជាការជួយសង្គ្រោះជីវិតប៉ុណ្ណោះទេ ប៉ុន្តែជាសារមួយបង្ហាញថា ប្រជាជនកម្ពុជាតែងតែនៅក្បែរ និងគាំទ្រជានិច្ចដល់កងកម្លាំងការពារជាតិ។







# លោកអ្នកឧកញ៉ាបណ្ឌិត ពុង ឃាវសែ ឧបត្ថម្ភថវិកា ៣លានដុល្លារ ជួយដល់កងទ័ពជួរមុខ និងជនភៀសសឹក




លោកអ្នកឧកញ៉ាបណ្ឌិត **ពុង ឃាវសែ** ប្រធានក្រុមប្រឹក្សាភិបាល នៃធនាគារ ប្រៃសណីយ៍កម្ពុជា បានប្រកាសចូលរួមឧបត្ថម្ភថវិកាចំនួន **៣.០០០.០០០ ដុល្លារអាមេរិក (បីលានដុល្លារ)** តាមរយៈ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ដើម្បីជួយដល់កងទ័ពជួរមុខ និងជនភៀសសឹក។

ការចូលរួមបរិច្ចាគថវិកាដ៏ច្រើនសន្ធឹកសន្ធាប់នេះ ធ្វើឡើងក្នុងគោលបំណងចម្បងដើម្បីជួយទ្រទ្រង់ និងលើកទឹកចិត្តដល់វីរកងទ័ពកម្ពុជាដ៏អង់អាចក្លាហាន ដែលកំពុងឈរជើងការពារបូរណភាពទឹកដីយ៉ាងរឹងមាំ នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ។ ទន្ទឹមនឹងនេះ ថវិកានេះក៏នឹងត្រូវយកទៅប្រើប្រាស់ដើម្បីជួយសង្គ្រោះ និងផ្គត់ផ្គង់ដល់បងប្អូនប្រជាពលរដ្ឋដែលបានរងផលប៉ះពាល់ និងក្លាយជាជនភៀសសឹកផងដែរ។

កាយវិការដ៏ថ្លៃថ្លារបស់ លោកអ្នកឧកញ៉ាបណ្ឌិត **ពុង ឃាវសែ** និង ធនាគារ ប្រៃសណីយ៍កម្ពុជា គឺជាសក្ខីភាពបង្ហាញពីស្មារតីស្នេហាជាតិដ៏មោះមុត ការចូលរួមទទួលខុសត្រូវខ្ពស់ក្នុងនាមវិស័យឯកជន និងការឈរនៅជាកម្លាំងចលករដ៏សំខាន់ជាមួយរាជរដ្ឋាភិបាល និងកងកម្លាំងប្រដាប់អាវុធ ក្នុងកាលៈទេសៈដែលជាតិត្រូវការ។



ធនាគារ កាណាឌីយ៉ា
加 華 銀 行
CANADIA BANK

ធនាគារ ប្រៃសណីយ៍កម្ពុជា
東埔寨郵政銀行 CAMBODIA POST BANK

# ប្រើប្រាស់ ប័ណ្ណ CSS CARD

## របស់ ធនាគារ កាណាឌីយ៉ា និង ធនាគារ ប្រៃសណីយ៍កម្ពុជា ដកប្រាក់នៅគ្រប់ម៉ាស៊ីន ATM របស់ស្ថាប័នទាំងពីរ

**ឥតគិតថ្លៃសេវា**




